ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អត្រាកំណែប្រឡងជ្រើសរើសគ្រូកម្រិតមូលដ្ឋាន
សម័យប្រឡង ០៤ វិច្ឆិកា ២០១៦
មុខវិជ្ជា៖ វប្បធម៌ទូទៅ

ប្រធាន: មានមតិខ្លះបានលើកឡើងថា វប្បធម៌ និងអារ្យធម៌ខ្មែរមានប្រភពមកពីប្រទេសឥណ្ឌា។ ក៏ប៉ុន្តែមានមតិខ្លះបានលើកឡើងថា មុននឹងទទួលយកវប្បធម៌ឥណ្ឌា ខ្មែរមានមូលដ្ឋានវប្បធម៌របស់ខ្លួនរួចជាស្រេចហើយ។ ចូរអ្នកពិភាក្សាលើមតិទាំងពីរ។(១០ពិន្ទុ)

១.សេចក្តីផ្តើម (១,00 ពិន្ទុ)

(០,៥០ពិន្ទុ) - លំនាំ : ជាតិសាសន៍នីមួយៗនៅលើលោកយើងនេះសុទ្ធតែមានវប្បធម៌ និងអារ្យធម៌រៀងខ្លួនតាំងពីដូនតាមក ក៏ប៉ុន្តែការរស់នៅតែងតែមានទំនាក់ទំនងគ្នាទៅវិញទៅមកជានិច្ច - - - - - -

(០,២៥ពិន្ទុ) - ចំណុល : មានមតិខ្លះបានលើកឡើងថា «វប្បធម៌ និងអារ្យធម៌ខ្មែរមានប្រភពមកពីប្រទេសឥណ្ឌា» ប៉ុន្តែមានមតិខ្លះបានលើកឡើងថា «មុននឹងទទួលយកវប្បធម៌ឥណ្ឌា ខ្មែរមានមូលដ្ឋានវប្បធម៌របស់ខ្លួនរួចជាស្រេចហើយ» ។

(០,២៥ពិន្ទុ) - ចំណោទ : - តើមតិទាំងពីរខាងលើនេះមួយណាត្រឹមត្រូវជាង? ឬ
- តើមតិទាំងពីរខាងលើនេះមួយណាខុសមួយណាត្រូវ?

២.តួសេចក្តី (៧,00 ពិន្ទុ)

(០,២៥ពិន្ទុ) - ឃ្លាភ្ជាប់ : ដើម្បីជាជំនួយដល់ការបកស្រាយមតិខាងលើនេះ ចាំបាច់ត្រូវយល់ពាក្យមួយចំនួនជាមុនសិន។

- ពន្យល់ពាក្យ : (០,៥០ពិន្ទុ)

(០,២៥ពិន្ទុ) + វប្បធម៌ : ការផ្សាំបណ្តុះ សាបព្រោះចំណេះវិជ្ជា និងប្រាជ្ញាស្មារតីឱ្យបានល្អតលាស់ ចម្រើនដោយវិទ្យាសាស្ត្រ ឬដោយសិល្បៈផ្សេងៗជាដើម ។

(០,២៥ពិន្ទុ) + អារ្យធម៌ : ធម៌ដែលនាំឱ្យកើតសេចក្តីសុខ សេចក្តីចម្រើនរបស់អរិយជន អ្នកមានទំនៀមទម្លាប់សណ្តាប់ធ្នាប់ល្អ បែបបទ រៀបរយ និងប្រកបដោយសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ស្របទៅតាមការរីកចម្រើន ដែលល្អប្រសើរឥតខ្ចោះ។

(០,៥០ពិន្ទុ) - ពន្យល់ន័យប្រធាន : តាមន័យរបស់ប្រធានមានន័យថា គឺការផ្សាំបណ្តុះ សាបព្រោះចំណេះវិជ្ជា និងប្រាជ្ញាស្មារតីឱ្យបានល្អតលាស់ ចម្រើនល្អតលាស់ ដែលនាំឱ្យកើតសេចក្តីសុខ សេចក្តីចម្រើនដល់ជនានុជន ដែលមានទំនៀមទម្លាប់ សណ្តាប់ធ្នាប់ល្អ បែបបទ រៀបរយ និងប្រកបដោយសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ ស្របទៅតាមការរីកចម្រើនរបស់សង្គម។

ក.បកស្រាយមតិស្រប (២,00 ពិន្ទុ)

វប្បធម៌ និងអារ្យធម៌ខ្មែរមានប្រភពមកពីប្រទេសឥណ្ឌា

- អំណះអំណាង : សាសនា ជំនឿ ឥទ្ធិពលព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា

(1) បតិស្រប ០,៥ - ព្រហ្មញ្ញសាសនា
០,៥ - ព្រះពុទ្ធសាសនា
០,៥ - [illegible]
០,៥ - [illegible]

(2) [illegible]
០,៥ - [illegible]
០,៥ - [illegible]
០,៥ - [illegible]
០,៥ - [illegible]
០,៥ - [illegible]

(3) [illegible]

(0,៥0ពិន្ទុ) + ព្រហ្មញ្ញសាសនា : ការគោរពលើអាទិទេព ពិធីសែនព្រេនបួងសួង លទ្ធិទេវរាជ(ការ)
រាជសម្បត្តិ)

(0,៥0ពិន្ទុ) + ពុទ្ធសាសនា : ទស្សនកម្មផល (បុណ្យ បាប) ពិសាខបូជា មាឃបូជា

(0,៥0ពិន្ទុ) + អក្សរសាស្ត្រ អក្សរសិល្ប៍ : បាលី សំស្ក្រឹត រឿងរាមកេរ្តិ៍ មហាភារតយុទ្ធ ទសជាតក

(0,៥0ពិន្ទុ) + រចនាបថប្រាសាទ : ប្រាសាទភ្នំឧទ្ទិសដល់ទេវៈ សិវលិង្គ និងយោនីនាងឧមា

ខ.បកស្រាយមតិផ្ទុយ(៣,00ពិន្ទុ)

មុននឹងទទួលយកវប្បធម៌ឥណ្ឌា ខ្មែរមានមូលដ្ឋានវប្បធម៌របស់ខ្លួនរួចជាស្រេចហើយ

- អំណះអំណាង

(0,៥0ពិន្ទុ) + ប្រវត្តិនគរភ្នំ : ខ្មែរមាននគរ មានព្រះនាងលីវយី ឬព្រះនាងសោមា ជាអ្នកគ្រប់គ្រងមាន
ក្បួនទ័ព មានអាវុធដូចជាធ្នូ ស្នា លំពែង ជាវ ជនជាតិ វប្បធម៌ ភាសា

(0,៥0ពិន្ទុ) + ដើមកំណើតខ្មែរ : អំបូរ ខ្មែរ-មន បានកើតឡើងដោយការកាត់ផ្សំរវាងពូកឥណ្ឌាណេស៊ី
យ៉ាង និងពូកមេឡាណេស៊ីយ៉ាង ហើយរស់នៅលើទឹកដីនេះតាំងពីបុរេប្រវត្តិ។

(1,៥0ពិន្ទុ) + កំណាយបុរេប្រវត្តិសាស្ត្រ : សម្ភារៈប្រើប្រាស់ដូចជា ផ្លែសន្ទូច ព្រួញ ឭថៅ កាំបិត
ពន្លាក ថ្មោង ចាន ភាជន៍ ទំហួ អង្កាំ

(0,៥0ពិន្ទុ) + ប្រពៃណីទំនៀមទម្លាប់ : ខ្មែរគោរពដូនតា ឪពុកម្តាយ គ្រូបាធ្យាយ អ្នកតា ដូន ពិធីសែន
ព្រេន លៀងអារក្ស ពិធីរៀបអាពាហ៍ពិពាហ៍ មានបទភ្លេង បទចម្រៀង ទំនុកច្រៀង

(0,៥0ពិន្ទុ) + អក្សរសាស្ត្រ អក្សរសិល្ប៍ : តាមសិលាចារឹកវ៉ៃកាញ់ រឿងព្រេងនិទាន អក្សរសិល្ប៍
ប្រជាប្រិយ

(0,៥0ពិន្ទុ) + សិល្បៈ : រចាំប្រជាប្រិយ រាំវង់ រាំក្បាច់ រចាំនេសាទ គោះត្រឡោក

(0,៧៥ពិន្ទុ) គ.សំយោគមតិ : ដោយសំអាងទៅលើសម្ភារៈប្រើប្រាស់ដែលរកឃើញនៅក្នុងស្ថានីយ៍ទាំង៦
តាមប្រវត្តិនគរភ្នំ ប្រពៃណីទំនៀមទម្លាប់ សិលាចារឹក រឿងព្រេង និងជំនឿដើមរបស់ខ្មែរ សឱ្យ
ឃើញថាខ្មែរពិតជាមានវប្បធម៌ និងអារ្យធម៌របស់ខ្លួនពិតប្រាកដមែនមុននឹងឥណ្ឌាចូលមក។

៣.សេចក្តីបញ្ចប់ (១,៥0 ពិន្ទុ)

(0,៥0 ពិន្ទុ) -វាយតម្លៃប្រធាន : ប្រធាននេះអាចឱ្យយើងប្រៀបធៀប និងដឹងអំពីដើមកំណើតនៃវប្បធម៌ អារ្យ
ធម៌ជាតិយើង។

(0,៥0 ពិន្ទុ) -បង្ហាញហេតុ : ជនជាតិណាក៏ដូចជនជាតិណាតែងទទួលឥទ្ធិពលបរទេស ក៏ប៉ុន្តែខ្មែរបានធ្វើនីយ
កម្មមុននឹងទទួលយកមកអនុវត្ត។

(0,៥0 ពិន្ទុ) -រោបល់ផ្ទាល់ខ្លួន : ទស្សនៈប្រធានដែលបានលើកឡើងថា មុននឹងទទួលយកវប្បធម៌ឥណ្ឌា
ខ្មែរមានមូលដ្ឋានវប្បធម៌របស់ខ្លួនជាស្រេចរួចហើយ ដូចដែលយើងបានធ្វើការបកស្រាយខាង
លើស្រាប់។

៤.រចនាបថ (0,៥0 ពិន្ទុ)

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៦

ប្រធានកំណែ

ញ៉ែប ពិសោរ

បានឃើញ និងឯកភាព

សាស្ត្រាចារ្យ